# ការិយាល័យឧត្តមស្នងការសហប្រជាជាតិ
# ទទួលបន្ទុកសិទ្ធិមនុស្ស

## សេវាប្រតិបត្តិការបច្ចេកទេស និង សេវាប្រឹក្សាយោបល់នៅក្នុងប្រទេសកម្ពុជា

### សេចក្តីសំរេចចិត្តរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លេខ ២០០៥/៧៧

*គណៈកម្មាធិការសិទ្ធិមនុស្ស*

*ដោយគិតពី* សេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ២០០៤/៧៩ ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០០៤ ព្រមទាំងសេចក្តីសំរេចចិត្តមុនៗដែលទាក់ទង ។

*សូមស្វាគមន៍* ចំពោះរបាយការណ៍របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (E/CN.4/2005/116) ព្រមទាំងរបាយការណ៍របស់លោកអគ្គលេខាអ.ស.ប ស្តីពីតួនាទី និងសមិទ្ធិផល ដែលការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សសំរេចបាន ក្នុងការជួយឧបត្ថម្ភដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយសិទ្ធិមនុស្ស (E/CN.4/2005/111) ។

*ដោយទទួលស្គាល់ថា* ប្រវត្តិដ៏សោកនាដកម្មនាពេលថ្មីៗនេះរបស់កម្ពុជា ដែលតម្រូវឱ្យមានការចាត់វិធានការជាពិសេស ដើម្បីធានាការពារសិទ្ធិមនុស្ស និងដើម្បីកុំឱ្យវិលត្រឡប់ទៅរកនយោបាយ និងទម្លាប់អនុវត្តន៍ចាស់ពីអតីតកាល ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោ-បាយដ៏ទូលំទូលាយមួយនូវជំលោះនៃប្រទេសកម្ពុជា ដែលបានចុះហត្ថលេខា នាទីក្រុងប៉ារីស កាលពីថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ ។

*សូមស្វាគមន៍* ព្រះរាជបន្ទូលរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នរោត្តម សីហមុនី នៅក្នុងឱកាសដែលព្រះអង្គទ្រង់ឡើងគ្រងរាជ្យ ដែលព្រះអង្គទ្រង់មានព្រះរាជបន្ទូលអំពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។

## I- តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ៈ

១- *សូមស្វាគមន៍* ការផ្ដល់សច្ចាប័នដោយប្រទេសកម្ពុជា លើកិច្ចព្រមព្រៀងដែលបានធ្វើឡើង រវាងអង្គការសហប្រជាជាតិ និង រដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតអង្គជំនុំជំរះវិសាមញ្ញ នៅក្នុងតុលាការកម្ពុជាដែលអនុវត្តយុត្តាធិការរបស់ខ្លួន ស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ កិច្ចដំណើរការត្រូវតាមច្បាប់ ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀង។

២- *សូមស្នើយ៉ាងទទូច* ដល់លោកអគ្គលេខាធិការអ.ស.ប និងរដ្ឋាភិបាលកម្ពុជាឱ្យចាត់វិធានការចាំបាច់គ្រប់បែបយ៉ាង ដើម្បីបង្កើតអង្គជំនុំជំរះនេះឱ្យបានឆាប់រហ័ស រួមទាំងការបំពេញកាតព្វកិច្ចផ្នែកច្បាប់ និងហិរញ្ញវត្ថុ។

៣- *សូមស្វាគមន៍* ចំពោះទង្វើ ដែលរដ្ឋជាច្រើនបានធ្វើការប្ដេជ្ញាចិត្តផ្ដល់ការជួយឧបត្ថម្ភ រួមមានការជួយគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកបុគ្គលិក ដល់អង្គជំនុំជំរះវិសាម័ញ្ញ ហើយសូមធ្វើការអំពាវនាវដល់សមាជិកនានានៃសហគមន៍អន្តរជាតិ ដើម្បីផ្ដល់ការជួយគាំទ្រទាំងនេះ ស្របតាមសេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ 57/228 B ចុះខែឧសភា ឆ្នាំ២០០៣ ហើយសូមស្នើយ៉ាងទទូចដល់លោកអគ្គលេខាធិការ សូមមេត្តាជូនដំណឹងថា សេចក្តីតម្រូវផ្នែកច្បាប់ ដើម្បីឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមានត្រូវបានគេគោរពតាមហើយ។

## II- លទ្ធិប្រជាធិបតេយ្យ និង សភាពការណ៍សិទ្ធិមនុស្ស

៤- *សូមស្វាគមន៍ ៈ*

(ក) ការបង្កើតរដ្ឋាភិបាលថ្មី កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ដោយផ្អែកលើលទ្ធផលនៃការបោះឆ្នោតទូទៅ ដែលបានប្រារព្ធធ្វើឡើង កាលពីខែកក្កដា ឆ្នាំ២០០៣។

(ខ) ការរីកចំរើនដែលប្រទេសកម្ពុជាបានធ្វើឱ្យសភាពការណ៍សិទ្ធិមនុស្សបានកាន់តែប្រសើរឡើង នៅក្នុងទសវត្សកន្លងមកនេះ ក្នុងវិស័យជាច្រើន ដោយសហការជាមួយអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា រួមទាំងសេរីភាពខាងសារព័ត៌មាន សេរីភាពខាងសាសនា ការប្រយុទ្ធប្រឆាំងពលកម្មកុមារ និងការធ្វើអាជីវកម្មផ្លូវភេទ និងការរីកចំរើនក្នុងការលើកស្ទួយស្ថាប័នប្រជាធិបតេយ្យ។

(គ) កិច្ចព្រមព្រៀងរបស់ប្រទេសកម្ពុជា តាមរយៈការចូលរួមនៅក្នុងក្រុមពិគ្រោះយោបល់ ស្តីពីប្រទេសកម្ពុជា ដើម្បីជំរុញឱ្យមានអភិបាលកិច្ចល្អ តាមរយៈការកំណត់ពេលសំរាប់អនុវត្ត (bench marks) និងការពិនិត្យជាប្រចាំ ព្រមទាំងសកម្មភាពផ្សេងទៀត រួមមានការអនុម័តសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ។

(ឃ) ការបន្តជាថ្មី នូវអនុស្សរណៈយោគយល់គ្នារវាងរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សំរាប់ការអនុវត្តន៍កម្មវិធីនៃកិច្ចសហប្រតិបត្តិការបច្ចេកទេស ស្តីពីបញ្ហាសិទ្ធិមនុស្ស និងជំរុញលើកទឹកចិត្តដល់ភាគីទាំងពីរ ឱ្យសហការគ្នាប្រកបដោយលក្ខណៈស្ថាបនា ដើម្បីធ្វើឱ្យសភាពការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា កាន់តែល្អប្រសើរឡើងថែមទៀត ។

៥- *សូមសំដែងនូវការព្រួយបារម្ភ :* ក្នុងខណៈដែលសំគាល់ឃើញការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា អំពីការរំលោភសិទ្ធិមនុស្ស ដែលនៅតែកើតមានជាបន្ត ជាពិសេសបញ្ហាទាំងឡាយដែលទាក់ទងនឹងនីតិរដ្ឋ តុលាការ ការជួញដូរមនុស្ស អំពើហឹង្សាលើសកម្មជននយោបាយ និងសកម្មជនស៊ីវិល បញ្ហានីទណ្ឌភាព និង អំពើពុករលួយ ។

៦- *ស្នើយ៉ាងទទូច* ដល់រដ្ឋាភិបាលកម្ពុជា សូមឱ្យ :

(ក) ពង្រឹងការខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការបង្កើតនូវនីតិរដ្ឋ ដូចជាការអនុម័ត និងការអនុវត្តច្បាប់ និងក្រមសំខាន់ៗសំរាប់បង្កើតសង្គមប្រជាធិបតេយ្យ និងដើម្បីបន្តចាត់ទុកជាបញ្ហាអាទិភាព រួមទាំងបញ្ហានីទណ្ឌភាព និងបង្កើនការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេត ជាបន្ទាន់ និងកាត់ទោសទៅតាមនិតិវិធីត្រឹមត្រូវរបស់ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ចំពោះជន ទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ រួមទាំងបទរំលោភសិទ្ធិមនុស្សផង ។

(ខ) បន្តពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ជាពិសេសក្នុងការធានាឯករាជ្យភាព ភាពមិនលំអៀង តម្លាភាព និងប្រសិទ្ធិភាពដល់ប្រព័ន្ធយុត្តិធម៌ទាំងមូល និងដើម្បីប្រយុទ្ធ ប្រឆាំងអំពើពុករលួយ និងបញ្ហានីទណ្ឌភាព ។

(គ) បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីលើកស្ទួយការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្ត្រី និងកុមារ និងបង្កើនកិច្ចខិតខំប្រឹងប្រែងថែមទៀត ដោយសហការជាមួយសហគមអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាជាគន្លឹះមួយចំនួន ដូចជាការជួញដូរមនុស្ស បញ្ហាទាក់ទងនឹងភាពក្រីក្រ អំពើហឹង្សាផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

(ឃ) ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការដោះស្រាយបញ្ហាកម្មសិទ្ធិដីធ្លីឱ្យបានស្មើភាពគ្នា និងឱ្យបានឆាប់រហ័ស ប្រកបដោយភាពត្រឹមត្រូវ និងដោយចំហ ស្របតាមស្មារតីនៃសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ក៏ដូចជាស្មារតីនៃច្បាប់ភូមិបាលផងដែរ ។

(ង) ចាត់វិធានការគ្រប់បែបយ៉ាង ដើម្បីអនុវត្តឱ្យបានសំរេចនូវកាតព្វកិច្ចរបស់ខ្លួន ក្រោមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងបន្តកិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ រួមមានការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។

(ច) បន្តបង្កើតបរិយាកាស ដែលជួយឱ្យសកម្មភាពនយោបាយបានដំណើរការ ដោយស្របច្បាប់ ព្រមទាំងជួយគាំទ្រដល់តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាឱ្យបានរឹងមាំ ។

(ឆ) បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីជំរុញឱ្យមានអភិបាលកិច្ចល្អថែមទៀត ។

**III-** **<u>សេចក្តីសន្និដ្ឋាន</u>**

៦- *សូមអញ្ជើញ* លោកអគ្គលេខាធិការអ.ស.ប អង្គការនានានៅក្នុងប្រព័ន្ធសហប្រជាជាតិ ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ព្រមទាំងសហគមន៍អន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលនានា ឱ្យបន្តជួយធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ ក៏ដូចជាការធានាការពារ និងលើកស្ទួយសិទ្ធិមនុស្សនៃជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជា រួមមានការជួយឧបត្ថម្ភ ក្នុងវិស័យនានាដូចជា :

(ក) ការរៀបចំព្រាងច្បាប់ចាំបាច់នានា ដើម្បីការពារ និងលើកស្ទួយសិទ្ធិមនុស្ស ។

(ខ) ការកសាងសមត្ថភាព ដើម្បីពង្រឹងស្ថាប័នច្បាប់ រួមមានការបង្កើនគុណភាពចៅក្រមព្រះរាជអាជ្ញា មេធាវី និង បុគ្គលិកតុលាការ ។

(គ) ការកសាងសមត្ថភាព ដើម្បីពង្រឹងស្ថាប័នជាតិ ក្នុងការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ និងការអនុវត្តច្បាប់ ក៏ដូចជាការផ្តល់ឧបករណ៍ចាំបាច់ ដើម្បីសំរេចគោលបំណងទាំងនេះ

(ង) ជួយធ្វើការវាយតំលៃ អំពីភាពរីកចំរើន ក្នុងវិស័យសិទ្ធិមនុស្ស ។

៨- *សូមស្នើ* ដល់លោកអគ្គលេខាធិការអ.ស.ប សូមជួយរាយការណ៍ជូនគណៈកម្មាធិការនៅក្នុងសម័យប្រជុំលើកទី៦២ (ហុកសិបពីរ) របស់ខ្លួន អំពីតួនាទី និងសមិទ្ធិផលនានា ដែលការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សសំរេចបានក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងអំពីអនុសាសន៍ដែល ធ្វើឡើងដោយលោកតំណាងពិសេសនៃអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លើបញ្ហាទាំងឡាយដែលស្ថិតក្នុងអាណត្តិរបស់លោក ។

៩- *សំរេច* បន្តធ្វើការពិនិត្យពិចារណារបស់ខ្លួន អំពីសភាពការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា នៅក្នុងសម័យប្រជុំលើកទី៦២ (ហុកសិបពីរ) របស់ខ្លួន ។

*សម័យប្រជុំលើកទី៥៩*

*ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៥*

[អនុម័តដោយគ្មានការបោះឆ្នោត  សូមមើលជំពូកទី XIX, E/CN.4/2005/L.10/Add.1 ]